សប្តាហ៍ទី
48

ការរស់ឡើងវិញរបស់ព្រះយេស៊ូ

ព្រះយេស៊ូបានឈ្នះសេចក្តីស្លាប់ ហើយមានព្រះជន្មរស់ឡើងវិញ!
តស់! មកគួរគំនួរលាក់កំបាំង ដើម្បីអបអរការរស់ឡើងវិញរបស់ព្រះយេស៊ូទាំងអស់គ្នា!

រឿងក្នុងព្រះគម្ពីរ

ព្រះយេស៊ូស្រឡាញ់យើងខ្លាំងណាស់ រហូតដល់ព្រះអង្គយាងទៅជាប់ឈើឆ្កាង។ ប៉ុន្តែ បីថ្ងៃក្រោយ ព្រះអង្គបានរស់ឡើងវិញ!

ព្រះយេស៊ូបានសុគត ប៉ុន្តែព្រះអង្គបានរស់ឡើងវិញ ហើយប្រទានជីវិតថ្មីដល់យើង។

ការរស់ឡើងវិញរបស់ព្រះយេស៊ូផ្តល់ក្តីសង្ឃឹមដល់យើង។

តស់! យើងចែករំលែកអំណរដ៏អស្ចារ្យនេះជាមួយអ្នកដទៃ។ យើងរួមគ្នាអរព្រះគុណសម្រាប់ការរស់ឡើងវិញរបស់ព្រះយេស៊ូ!

«ហេតុអ្វីបានជានាងនាំគ្នាមករកព្រះអង្គដែលមានព្រះជន្មរស់ ក្នុងចំណោមមនុស្សស្លាប់ដូច្នេះ? ទ្រង់មិនគង់នៅទីនេះទេ ព្រះជាម្ចាស់បានប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញហើយ។» [លូកា២៤:៥-៦]



វត្ថុបំណង

- យល់ពីព្រឹត្តិការណ៍នៃការរស់ឡើងវិញរបស់ព្រះយេស៊ូ
- ទទួលបានក្តីអំណរនៃការរស់ឡើងវិញ តាមរយៈសកម្មភាពគំនូរលាក់កំបាំង
- ប្រើប្រាស់ពណ៌ទឹកចម្រុះដើម្បីបញ្ចេញគំនិតច្នៃប្រឌិត
- បង្ហាញពីចិត្តស្រឡាញ់ និងអំណរចំពោះព្រះយេស៊ូ។

សម្ភារៈ



របៀបធ្វើសកម្មភាព

1. ប្រើកូលំរទៀន (ពណ៌ស លឿង ផ្ទៃមេឃ) គូររូបព្រះយេស៊ូធំមួយនៅលើក្រដាសគំនូរ។
2. រៀបចំលាយទឹកថ្នាំពណ៌ឱ្យបានច្រើនពណ៌។
3. យកជក់ជ្រលក់ថ្នាំពណ៌ទឹក មកជាប់ពីលើក្រដាសគំនូរទាំងមូលដោយសេរី។
4. នៅពេលដែលថ្នាំពណ៌ទឹកស្ងួត រូបព្រះយេស៊ូនឹងលេចចេញមកយ៉ាងច្បាស់!






ការពង្រីកសកម្មភាព

- បង្កើតគំនូរដោយប្រើប្រាស់ពណ៌ច្រើនយ៉ាង។
- សាកល្បងប្រើសម្ភារៈផ្សេងៗដូចជា អេប៉ុង ម្រាមដៃ ឬប្រាសដុសធ្មេញ ដើម្បីជ្រលក់ពណ៌។
- អរគុណព្រះយេស៊ូរួមគ្នា សម្រាប់អំណរនៃការរស់ឡើងវិញរបស់ព្រះអង្គ។
- ធ្វើប័ណ្ណអធិស្ឋានដ៏ស្រស់ស្អាតមួយ ដើម្បីអរព្រះគុណព្រះយេស៊ូសម្រាប់ការរស់ឡើងវិញរបស់ព្រះអង្គ។

Tip សម្រាប់គ្រូ

- ប្រាប់កុមារឱ្យប្រើកូលំរទៀនដែលមានពណ៌ភ្លឺៗ ដូចជាពណ៌ស លឿង និងផ្ទៃមេឃ សម្រាប់គូររូប ដើម្បីឱ្យគំនូរអាចំកំបាំងលេចចេញមកបានច្បាស់ នៅពេលជាត់ថ្នាំពណ៌ទឹកពីលើ។
- លើកទឹកចិត្តឱ្យកុមារប្រើពណ៌ដោយសេរី។
- សរសើរកុមារ ហើយពោលម្លឹកថា៖ "ព្រះយេស៊ូបានសុគត ហើយរស់ឡើងវិញ! ហាលេលូយ៉ា! តស់! យើងចែករំលែកអំណរនេះទាំងអស់គ្នា!"